**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៥ សហវ

ថ្ងៃសុក្រ ៤កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០

# សេចក្តីណែនាំ

## ស្តីពី

## ការបើកគណនីរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គណនីរបស់រដ្ឋទេយ្យករបុរេប្រទាន គណនីរបស់រដ្ឋទេយ្យករចំណូល និងគណនីរបស់ភ្នាក់ងារបើកផ្តល់នៅធនាគារ

យោងអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ប្រកាសលេខ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ប្រកាសលេខ០១៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន គណនេយ្យរដ្ឋទេយ្យចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល សេចក្តីណែនាំលេខ០១៨ សហវ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការតែងតាំងភ្នាក់ងារបើកផ្តល់ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល និងលិខិតលេខ១០០៧១ សហវ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តថវិកានៅគ្រឹះស្ថានសាធារណៈរដ្ឋបាល។

ដើម្បីលើកកម្ពស់តម្លាភាព គណនេយ្យភាព និងមានប្រសិទ្ធភាពបន្ថែមទៀតលើការប្រើប្រាស់គណនីរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គណនីរបស់រដ្ឋទេយ្យករបុរេប្រទាន គណនីរបស់រដ្ឋទេយ្យករចំណូល និងគណនីរបស់ភ្នាក់ងារបើកផ្តល់នៅធនាគារពាណិជ្ជដៃគូ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម៖

**១.**ត្រូវបានអនុញ្ញាតឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាល បើកគណនីនៅធនាគារពាណិជ្ជដៃគូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រាក់រៀល និង/ឬ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ចំណូលផ្ទាល់។ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំលិខិតស្នើសុំការអនុញ្ញាតបើកគណនីទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ដោយត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

-អង្គភាពបើកគណនី៖ ឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាល

-ឈ្មោះគណនី៖ ឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាល-ប្រតិបត្តិការចំណូល ចំណាយ

-ម្ចាស់គណនី៖ នាយក និងនាយករង (អ្នកទទួលសិទ្ធិ) និងគណនេយ្យករ

-លក្ខខណ្ឌនៃការប្រើប្រាស់៖ មានហត្ថលេខាចំនួន ២នាក់ គឺហត្ថលេខារបស់នាយក ឬ នាយករង និងហត្ថលេខារបស់គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលដោយប្រើប្រាស់ត្រារបស់អង្គភាព។ ក្នុងករណីមានការប្រគល់សិទ្ធិជូននាយករងធ្វើប្រតិបត្តិការក្នុងគណនីនេះ ត្រូវមានលិខិតប្រគល់សិទ្ធិពីនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

២.ក្នុងករណីចាំបាច់ គ្រឹះស្ថានសាធារណៈរដ្ឋបាលអាចបើកគណនីរបស់រដ្ឋទេយ្យករបុរេប្រទានជាប្រាក់រៀល និង/ឬ ជាប្រាក់ដុល្លារអាមេរិក នៅធនាគារពាណិជ្ជដៃគូ។ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំលិខិតស្នើសុំការអនុញ្ញាតបើកគណនីទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ដោយត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម÷

-អង្គភាពបើកគណនីៈ ឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាល

-ឈ្មោះគណនីៈ ឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាល-រដ្ឋទេយ្យបុរេប្រទាន

-ម្ចាស់គណនីៈ រដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង

-លក្ខខណ្ឌនៃការប្រើប្រាស់ៈ មានហត្ថលេខាចំនួន ០១នាក់ គឺហត្ថលេខារបស់រដ្ឋទេយ្យករបុរេប្រទាន ឬ របស់រដ្ឋទេយ្យករបុរេប្រទានរង

-ក្នុងករណីមានការប្រគល់សិទ្ធិជូនរដ្ឋទេយ្យករបុរេប្រទានរងធ្វើប្រតិបត្តិការក្នុងគណនីនេះ ត្រូវមានលិខិតប្រគល់សិទ្ធិពីរដ្ឋទេយ្យករបុរេប្រទាន ដោយមានការឯកភាពពីនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល

-ការដកប្រាក់ ឬ ការផ្ទេរប្រាក់ពីគណនីរដ្ឋទេយ្យករបុរេប្រទាននៅធនាគារពាណិជ្ជដៃគូ ពុំមានការប្រើប្រាស់ត្រាទេ

-ក្នុងករណីមានការផ្លាស់ប្តូរគំរូហត្ថលេខារបស់រដ្ឋទេយ្យករបុរេប្រទាន ឬ រដ្ឋទេយ្យករបុរេប្រទានរង នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំលិខិតស្នើសុំការអនុញ្ញាតប្តូរគំរូហត្ថលេខាជាថ្មីរបស់រដ្ឋទេយ្យករបុរេប្រទាន និង/ឬ រដ្ឋទេយ្យករបុរេប្រទានរងទៅធនាគារពាណិជ្ជដៃគូ។

-ក្នុងករណីមានការផ្លាស់ប្តូររដ្ឋទេយ្យករបុរេប្រទាន ឬ រដ្ឋទេយ្យករបុរេប្រទានរង គឺត្រូវមានការតែងតាំងជាថ្មីដោយប្រកាសអន្តរក្រសួង។ ក្រោយពីមានប្រកាសអន្តរក្រសួងហើយ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំលិខិតស្នើសុំប្តូរគំរូហត្ថលេខារបស់រដ្ឋទេយ្យករបុរេប្រទាន និង/ឬ រដ្ឋទេយ្យករបុរេប្រទានរងថ្មីទៅធនាគារពាណិជ្ជដៃគូ។

៣.ក្នុងករណីចាំបាច់ គ្រឹះស្ថានសាធារណៈរដ្ឋបាលអាចបើកគណនីរបស់រដ្ឋទេយ្យករចំណូលជាប្រាក់រៀល និង/ឬ ជាប្រាក់ដុល្លារអាមេរិក នៅធនាគារពាណិជ្ជដៃគូ។ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំលិខិតស្នើសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ដោយត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោមៈ

-អង្គភាពបើកគណនីៈ ឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាល

-ឈ្មោះគណនីៈ ឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាល-រដ្ឋទេយ្យចំណូល

-ម្ចាស់គណនីៈ រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង

-លក្ខខណ្ឌនៃការប្រើប្រាស់ៈ មានហត្ថលេខាចំនួន ០១នាក់ គឺហត្ថលេខារបស់រដ្ឋទេយ្យករចំណូល ឬ របស់រដ្ឋទេយ្យករចំណូលរង។ ក្នុងករណីមានការប្រគល់សិទ្ធិជូនរដ្ឋទេយ្យករចំណូលរងធ្វើប្រតិបត្តិការក្នុងគណនីនេះ ត្រូវមានលិខិតប្រគល់សិទ្ធិពីរដ្ឋទេយ្យករចំណូល ដោយមានការឯកភាពពីនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល

-ការដកប្រាក់ ឬ ការផ្ទេរប្រាក់ពីគណនីរដ្ឋទេយ្យករចំណូលនៅធនាគារពាណិជ្ជដៃគូ ពុំមានការប្រើប្រាស់ត្រាទេ

-ក្នុងករណីមានការផ្លាស់ប្តូរគំរូហត្ថលេខារបស់រដ្ឋទេយ្យករចំណូល ឬ រដ្ឋទេយ្យករចំណូលរង នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំលិខិតស្នើសុំប្តូរគំរូហត្ថលេខាថ្មីរបស់រដ្ឋទេយ្យករចំណូល និង/ឬ រដ្ឋទេយ្យករចំណូលរងទៅធនាគារពាណិជ្ជដៃគូ

-ក្នុងករណីមានការផ្លាស់ប្ដូររដ្ឋទេយ្យករចំណូល ឬ រដ្ឋទេយ្យករចំណូលរង គឺត្រូវមានការតែងតាំងជាថ្មី ដោយប្រកាសអន្តរក្រសួង។ ក្រោយពីមានប្រកាសតែងតាំងរបស់អន្តរក្រសួងហើយ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំលិខិតស្នើសុំប្ដូរគំរូហត្ថលេខារបស់រដ្ឋទេយ្យករចំណូល និង/ឬ រដ្ឋទេយ្យករចំណូលរងថ្មីទៅធនាគារពាណិជ្ជដៃគូ។

៤.ត្រូវបានអនុញ្ញាតឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាល បើកគណនីរបស់ភ្នាក់ងារបើកផ្ដល់ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលជាប្រាក់រៀល និង/ឬ ជាប្រាក់ដុល្លារអាមេរិក នៅធនាគារពាណិជ្ជដៃគូ សម្រាប់ធ្វើប្រតិបត្តិការប្រាក់បៀវត្ស ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភ ប្រាក់បេសកកម្ម ប្រាក់បុរេប្រទាន និងប្រាក់ចំណាយពិធីបុណ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំលិខិតស្នើសុំការអនុញ្ញាតបើកគណនីទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ដោយត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម÷

-អង្គភាពបើកគណនីៈ ឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាល

-ឈ្មោះគណនីៈ ឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាល-ប្រាក់បៀវត្ស កម្រៃ និងឧបត្ថម្ភផ្សេងៗ

-ម្ចាស់គណនីៈ ភ្នាក់ងារបើកផ្ដល់ និងភ្នាក់ងារបើកផ្ដល់ជំនួស

-លក្ខខណ្ឌនៃការប្រើប្រាស់ៈ មានហត្ថលេខាចំនួន ០១នាក់ គឺហត្ថលេខារបស់ភ្នាក់ងារបើកផ្ដល់ ឬ ភ្នាក់ងារបើកផ្ដល់ជំនួស។ ក្នុងករណីមានការប្រគល់សិទ្ធិជូនភ្នាក់ងារបើកផ្ដល់ជំនួសធ្វើប្រតិបត្តិការក្នុងគណនីនេះ ត្រូវមានលិខិតប្រគល់សិទ្ធិពីភ្នាក់ងារបើកផ្ដល់ ដោយមានការឯកភាពពីនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល

-គោលការណ៍សម្រាប់អនុវត្តការងារបើកផ្ដល់ ក្រៅពីខ្លឹមសារដែលបានចែងនៅចំណុចទី៤នេះ គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំលេខ០១៨ សហវ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីការតែងតាំងភ្នាក់ងារបើកផ្ដល់ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

៥.ករណីពុំទាន់បានបំពេញតាមលក្ខខណ្ឌខាងលើ (ដូចចំណុចទី១ ទី២ ទី៣ និងទី៤) នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំលិខិតស្នើសុំការអនុញ្ញាតទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីបើកគណនី ឬ ប្ដូរគំរូហត្ថលេខាថ្មី នៅធនាគារពាណិជ្ជដៃគូ។ រាល់ការបើកគណនី ឬ ប្ដូរគំរូហត្ថលេខានៅធនាគារពាណិជ្ជដៃគូ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវប្រគល់គំរូហត្ថលេខា ជូនគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួន ០១ច្បាប់ និងជូនរតនាគារពាក់ព័ន្ធចំនួន ០១ច្បាប់ (ច្បាប់ថតចម្លង ដែលមានការបញ្ជាក់ទទួលស្គាល់ពីនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល)។

ទទួលបានសេចក្ដីណែនាំនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី អគ្គនាយក នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល** ត្រូវអនុវត្តការងារនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ចម្លងជូនៈ**
-ក្រសួង ស្ថាប័ន អាណាព្យាបាលបច្ចេកទេស
-អគ្គនាយកដ្ឋានថវិកា
"ដើម្បីជ្រាប"
-អគ្គនាយកដ្ឋានរតនាគារជាតិ
-ធនាគារពាណិជ្ជដៃគូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
"ដើម្បីសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**